**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 22-Sep-2011, 15:50
CMS/CFO: Kauv Keoratanak

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ:/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើបន្ថែមរបស់សហព្រះរាជអាជ្ញាសុំការណែនាំពាក់ព័ន្ធចេតនារបស់ជនជាប់ចោទទាក់ទងនឹងការផ្តល់សក្ខីកម្ម**

---

| ដាក់ដោយ៖ | ផ្ញើជូន៖ | ផ្ញើជូន៖ |
|---|---|---|
| **សហមេធាវីរបស់លោក អៀង សារី** | **អង្គជំនុំជម្រះសាលាដំបូង** | **សហព្រះរាជអាជ្ញា** |
| លោក អាង ឧត្តម | ចៅក្រម និល ណុន | លោកស្រី ជា លាង |
| លោក Michael G. KARNAVAS | ចៅក្រម យូរ ឧត្តរ៉ា | លោក Andrew CAYLEY |
| | ចៅក្រម យ៉ា សុខន | |
| | ចៅក្រម Silvia CARTWRIGHT | **ក្រុមមេធាវីការពារក្តីទាំងអស់** |
| | ចៅក្រម Jean-Marc LAVERGNE | **ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់** |
| | ចៅក្រមបំរុង ធូ មណី | |
| | ចៅក្រមបំរុង Claudia FENZ | |

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) តទៅនេះសូមដាក់ចម្លើយតបទៅនឹងសំណើបន្ថែមរបស់សហព្រះរាជអាជ្ញាសុំការណែនាំ ពាក់ព័ន្ធនឹងចេតនារបស់ជនជាប់ចោទទាក់ទងនឹងការផ្តល់សក្ខីកម្ម (“សំណើ”)[1] ។ សារណាឆ្លើយតបនេះត្រូវធ្វើឡើងជាចាំបាច់ ដោយហេតុថាសំណើនេះមិនមានមូលដ្ឋាននៅក្នុងច្បាប់។ ម្យ៉ាងទៀត សំណើនេះលើកឡើងគោលជំហរជាសម្មតិកម្មដែលជម្រុញឡើងដោយសហព្រះរាជអាជ្ញា ។

## I ចម្លើយតប

### ក. សំណើនេះមិនមានមូលដ្ឋាននៅក្នុងច្បាប់

១. សហព្រះរាជអាជ្ញាអះអាងថា “លក្ខណៈមួយនៃនីតិវិធីតាមប្រព័ន្ធច្បាប់ស៊ីវិលដែលនៅជាធរមាននៅចំពោះមុខ អវតក ដែលថាជនជាប់ចោទត្រូវផ្តល់សក្ខីកម្មនៅពេលចាប់ផ្តើមសវនាការ”[2] ។ នៅក្នុងការដាក់ឯកសារលើកមុនទាក់ទងនឹងបញ្ហាដដែល សហព្រះរាជអាជ្ញាអះអាងថា “ការណ៍នេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងរចនាសម្ព័ន្ធនៃបទប្បញ្ញត្តិពាក់ព័ន្ធទាំងឡាយនៃវិធានផ្ទៃក្នុង...ហើយលំដាប់លំដោយនៃដំណើរការនីតិវិធីត្រូវបានអនុម័តដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងករណី០០១”[3]។ សហព្រះរាជអាជ្ញាកត់សម្គាល់ថា វិធាន/មាត្រា សម្រាប់ការតាំងសំណួរទៅជនសង្ស័យ ចែងមុន វិធាន/មាត្រា ស្តីពីការស្តាប់ចម្លើយរបស់ភាគីដទៃទៀត និងសាក្សីនានា នៅក្នុងវិធានផ្ទៃក្នុង និងក្រមព្រហ្មទណ្ឌកម្ពុជា ដូច្នេះជនជាប់ចោទផ្តល់សក្ខីកម្មនៅពេលចាប់ផ្តើមសវនាការ[4] ។

២. ជាបឋម ទាំងវិធានផ្ទៃក្នុង ឬក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនមានចែងពីលំដាប់លំដោយក្នុងការតាំងសំណួរដល់ជនជាប់ចោទ ឬស្តាប់ចម្លើយសាក្សី អ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណីទេ ។ នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលភាគច្រើន ជនជាប់ចោទត្រូវបានអនុញ្ញាតឲ្យធ្វើសេចក្តីថ្លែងការណ៍នៅ

---

[1] សំណើរបស់សហព្រះរាជអាជ្ញាសុំការណែនាំបន្ថែមទាក់ទងនឹងបំណងប្រាថ្នារបស់ជនជាប់ចោទ ទាក់ទងនឹងការធ្វើសក្ខីកម្ម ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១១ E101/1។

[2] ដូចខាងលើ នៅកថាខណ្ឌទី ៣។

[3] សំណើរបស់សហព្រះរាជអាជ្ញាសុំការណែនាំទាក់ទងនឹងបំណងប្រាថ្នារបស់ជនជាប់ចោទ ទាក់ទងនឹងការធ្វើសក្ខីកម្ម ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០១១ E101 ។

[4] ដូចខាងលើ ។

ពេលណាមួយក្នុងអំឡុងពេលសវនាការ[5] ។ ទាំងវិធានផ្ទៃក្នុង ក៏ដូចជាក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនបានហាមឃាត់ជនជាប់ចោទណាមួយពីការផ្តល់សក្ខីកម្មនៅដំណាក់កាលក្រោយៗនៃសវនាការនោះទេ ។ ទីពីរ តាមន័យតក្កវិជ្ជារបស់ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមានគុណវិបត្តិ ។ បើមើលពីខាងក្រៅ វិធាន ៨៤ និយាយពីការចូលខ្លួនរបស់សាក្សី និងអ្នកជំនាញ[6] ។ វិធាន ៨៤ អនុវត្តមុនវិធាន ៩០ ដែលដោះស្រាយចំពោះការតាំងសំណួរទៅជាប់ចោទ។ ប្រសិនតាមន័យតក្កវិជ្ជារបស់ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ត្រូវបានអនុញ្ញាត នោះសាក្សី និងអ្នកជំនាញគប្បីបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៅមុខការសាកសួរជនជាប់ចោទ ។ ទីបី ករណី ០០១ មិនយកមកអនុវត្តជាសទិសភាពជាមួយករណី ០០២ ទក់ទងនឹងការសាកសួរជនជាប់ចោទបានទេ។ ករណី០០១ គឺជាការសារភាពទោសកំហុសយ៉ាងប្រសិទ្ធិ។ ឌុច ត្រៀមលក្ខណៈរួចជាស្រេច និងមានឆន្ទៈនិយាយចាប់តាំងពីការចាប់ផ្តើមសវនាការមកម្លះ ។ ចំពោះករណី ០០២ វិញ គឺជាការជំនុំជម្រះប្រកបដោយតវ៉ាជំទាស់ ។

៣. សហព្រះរាជអាជ្ញាអះអាងថា “ពេលវេលាសម្រាប់ជនជាប់ចោទធ្វើការថ្លែងពីបំណងរបស់ខ្លួនទាក់ទងនឹងការផ្តល់ភស្តុតាង គឺនៅពេលនេះហើយ”[7]។ នេះគ្រាន់តែជាអះអាងដោយមិនបានផ្អែកលើច្បាប់ណាមួយនោ ។ ទាំងវិធានផ្ទៃក្នុង ឬក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនបានហាមឃាត់ជនជាប់ចោទណាមួយពីការបង្ហាញបំណងរបស់ពួកគេ ក្នុងការផ្តល់សក្ខីកម្មនៅដំណាក់កាលក្រោយៗនៃសវនាការនោះទេ ។

---

[5] នីតិវិធីនៅតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន បើបីជាតុលាការនេះប្រតិបត្តិតាមច្បាប់ស៊ីវិលបែបប្រពៃណីទាក់ទងនឹងការធ្វើសេចក្តីថ្លែងរបស់ជនជាប់ចោទ ក៏វាតំណាងឲ្យការលាយបញ្ចូលគ្នានៃច្បាប់ច្បាប់ស៊ីវិល និងច្បាប់កុម៉ង់ឡូពាក់ព័ន្ធនឹងបញ្ហានេះដែរ។ វិធាន ១៤៤(ក) ចែងថាជនជាប់ចោទ “អាចធ្វើសេចក្តីថ្លែងទៅកាន់អង្គជំនុំជម្រះសាលាដំបូងនៅគ្រប់ដំណាក់កាលនៃនីតិវិធី ឲ្យតែសេចក្តីថ្លែងនេះពាក់ព័ន្ធទៅនឹងករណី”។ វិធាននេះស្របគ្នានឹងច្បាប់ស៊ីវិលភាគច្រើន ដែលអនុញ្ញាតឲ្យជនជាប់ចោទធ្វើសេចក្តីថ្លែង រួមទាំងការធ្វើការអង្កេតលើដំណើរការនីតិវិធី នៅចំណុចណាមួយក្នុងអំឡុងពេលសវនាការ” ។ Colleen M. Rohan, *Rules Governing the Presentation of Testimonial Evidence*, in KARIM A. A. KHAN, CAROLINE BUISMAN AND CHRISTOPHER GOSNELL, PRINCIPLES OF EVIDENCE IN INTERNATIONAL CRIMINAL JUSTICE (OXFORD UNIVERSITY PRESS, 2010), នៅទំព័រ ៥២៦ ។

[6] ឧបទាហរណ៍ វិធាន ៨៤(៣) ចែងថា “ក្នុងពេលសវនាការ ភាគីនីមួយៗអាចស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងស្តាប់សាក្សីណាម្នាក់ដែលមានវត្តមាននៅក្នុងបន្ទប់សវនាការដែលសាក្សីនោះមិនធ្លាប់ត្រូវបានកោះហៅឱ្យមកផ្តល់សក្ខីកម្មនៅឡើយ”

[7] សំណើ នៅកថាខណ្ឌទី៥ ។

## ខ. សំណើនេះ គឺជារឿងលាក់ពុត

៤. សហព្រះរាជអាជ្ញាបានលើកសំណើនេះនៅឱកាសពីរដងដាច់ដោយឡែកពីគ្នា[8]។ សហព្រះរាជអាជ្ញាប្រកាន់ភ្ជាប់នូវជំហរថា:

> ការលើកឡើងនូវបញ្ហាដូចៗគ្នាតាមផ្លូវច្បាប់ នៅក្នុងការដាក់ឯកសារជាបន្តជាបន្ទាប់នោះ គឺមិនត្រឹមតែច្រំដែលនោះទេ វាជាការមិនគោរពដល់ដំណើរការនៃការធ្វើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ និងការដាក់ទម្ងន់ដែលមិនចាំបាច់ទៅលើពេលវេលា និងធនធានរបស់អង្គជំនុំជម្រះសាលាដំបូង និងភាគីនានាផងដែរ[9] ។

៥. ជំហរនេះ គឺជារឿងលាក់ពុតបើតាមសំណើច្រំដែលរបស់សហព្រះរាជអាជ្ញា ទៅកាន់អង្គជំនុំជម្រះសាលាដំបូងណែនាំជនជាប់ចោទបង្ហាញបំណងថាតើពួកគេនឹងផ្តល់សក្ខីកម្មដែរ ឬអត់នោះ ។ សហព្រះរាជអាជ្ញាមានចេតនាឲ្យអង្គជំនុំជម្រះ ប្រព្រឹត្តមកលើខ្លួនឲ្យបានច្រើនជាងមេធាវីការពារក្តី។ អង្គជំនុំជម្រះគប្បីទប់ទល់នឹងការប្រឹងប្រែងលួងលោមរបស់សហព្រះរាជអាជ្ញាដើម្បីអនុវត្តអ្វីដែលគួរប្រើទៅលើភាគីម្ខាង តែមិនគួរប្រើទៅលើភាគីម្ខាងទៀត (double standard)។ តាមពិតទៅ នេះគឺជាការដែលអាចយល់បានថា តើហេតុអ្វីបានជានៅពេលមានសំណើសុំធ្វើវិសោធនកម្មលើវិធានផ្ទៃក្នុង ត្រូវបានលើកឡើងនៅកិច្ចប្រជុំពេញអង្គទាក់ទងនឹងការដាក់ទណ្ឌកម្មលើមេធាវីការពារក្តីនៅក្នុងស្ថានភាពមួយចំនួន តែទណ្ឌកម្មបែបហ្នឹងមិនអនុវត្តចំពោះព្រះរាជអាជ្ញាផង។ វិធានបែបនេះត្រូវបានបដិសេធ ។ វិធានទាក់ទងនឹងវិន័យ និងការដាក់ទណ្ឌកម្ម ត្រូវតែអនុវត្តស្មើៗគ្នាចំពោះភាគីទាំងអស់ ។

៦. សហព្រះរាជអាជ្ញា បានរំលឹកមេធាវីការពារក្តីនៅពេលថ្មីៗនេះពីអនុសាសន៍របស់អង្គជំនុំជម្រះសាលាដំបូងថា ប្រាក់កម្រៃរបស់មេធាវីការពារក្តីត្រូវដកហូតចំពោះការដាក់ឯកសារច្រើន... ដែលគ្មានមូលដ្ឋានច្បាប់ និងមានប្រសិទ្ធិភាពតិចតួចក្រៅតែពីការដាក់បន្ទុកមកលើអង្គជំនុំជម្រះ និង

---

[8] ប្រតិចារិតនៃកិច្ចប្រជុំរៀបចំសវនាការ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១១ E1/2.1 នៅទំព័រ ៥៤-៥៥, សំណើរបស់សហព្រះរាជអាជ្ញាសុំការណែនាំពាក់ព័ន្ធនឹងបំណងរបស់ជនជាប់ចោទទាក់ទងនឹងការផ្តល់សក្ខីកម្ម ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ E101 ។

[9] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងការជំទាស់របស់ អៀង សារី ចំពោះភាពអាចទទួលយកបាននៃប្រភេទឯកសារមួយចំនួន ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១១, ឯកសារ E114/1 ត្រង់កថាខណ្ឌទី២១។

សេវាបកប្រែតែប៉ុណ្ណោះ[10]។ ខណៈដែលមេធាវីការពារក្តីលើកសរសើរសហព្រះរាជអាជ្ញា ចំពោះការប្រឹងប្រែងរបស់ខ្លួនក្នុងបញ្ហានេះ តែជាធម្មតាគេត្រូវគិតថាសហព្រះរាជអាជាក៏ទទួលរង នៅផលវិបាកដូចគ្នា ចំពោះអ្វីដែលសហព្រះរាជអាជ្ញា ព្យាយាមតស៊ូមតិដើម្បីអោយប្រព្រឹត្តចំពោះ មេធាវីការពារក្តី។

**អាស្រ័យដូចបានបញ្ជាក់ក្នុងមូលហេតុខាងលើ** មេធាវីការពារក្តីស្នើសុំឲ្យអង្គជំនុំជម្រះបដិសេធចោល សំណើនេះ។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **២២** ខែ **កញ្ញា** ឆ្នាំ **២០១១**

**អាង ឧត្តម** **Michael G. KARNAVAS**

សហមេធាវីរបស់លោក **អៀង សារី**

[10] ដូចខាងលើ ត្រង់កថាខណ្ឌទី១៨ សម្រង់ពីអនុស្សារណៈ ពីប្រធានអង្គជំនុំជម្រះសាលាដំបូង និល ណុន ទៅកាន់ភាគីទាំងអស់ ក្នុងករណី០០១ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១១ ឯកសារ E74។